**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

កាលពីថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានដឹកនាំប្រតិភូក្រសួង ទៅបំពេញទស្សនកិច្ចនៅប្រទេសម៉ាឡេស៊ី និងបានអញ្ជើញជាអធិបតីភាពក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចព្រមព្រៀង (Memorandum of Agreement) ស្តីពីយន្តការការពារ និងផ្តល់សុខុមាលភាពជូនពលករកម្ពុជាធ្វើការនៅប្រទេសម៉ាឡេស៊ី រវាងអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាគមទីភ្នាក់ងារពលករបរទេសនៅម៉ាឡេស៊ី។

អនុស្សរណៈនៃកិច្ចព្រមព្រៀងនេះ គឺជាឧបករណ៍បន្ថែមលើអនុស្សរណៈយោគយល់គ្នា រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងធនធានមនុស្សម៉ាឡេស៊ី។ អនុស្សរណៈនៃកិច្ចព្រមព្រៀងនេះនឹងៈ

១- ត្រួតពិនិត្យមើលលក្ខណៈសម្បត្តិ និងប្រវត្តិរបស់និយោជកម៉ាឡេស៊ីឱ្យស្របតាមបទប្បញ្ញត្តិម៉ាឡេស៊ីដែលតម្រូវក្នុងការប្រើប្រាស់ពលករបរទេស។

២- រៀបចំគ្រប់គ្រងប្រព័ន្ធទិន្នន័យពលករទេសន្តរប្រវេសន៍កម្ពុជា និងទិន្នន័យរបស់និយោជក ចាប់តាំងពីចុះឈ្មោះ ពេលចុះកិច្ចសន្យាការងារ រហូតដល់ពេលធ្វើមាតុភូមិនិវត្តន៍។

៣- កំណត់យន្តការទស្សនកិច្ចដល់ទីកន្លែងធ្វើការរបស់ពលករ ពលការិនី រៀងរាល់ត្រីមាស ដោយទីភ្នាក់ងារនៃប្រទេសទាំងពីរ ដើម្បីធានាថាពលករ ពលការិនី ទទួលបាននូវសុខុមាលភាព និងការការពារសិទ្ធិស្របតាមច្បាប់។

៤- ផ្តល់ការបណ្តុះបណ្តាល និងផ្តល់ទូរសព្ទដៃសម្រាប់ទំនាក់ទំនងរវាងស្ត្រីជំនួយការមេផ្ទះ និងក្រុមគ្រួសារ ក៏ដូចជាមន្ត្រីមានសមត្ថកិច្ចកម្ពុជា។

៥- រៀបចំឲ្យមានធានារ៉ាប់រងគ្រោះថ្នាក់ការងារ ធានារ៉ាប់រងសុខភាពដល់ពលករ ពលការិនី មុនពេលចាប់ផ្តើមការងារ។

៦- ផ្តល់សេវាមេធាវី និងផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្ននៅពេលមានវិវាទកើតឡើង។

៧- ផ្តល់ការបណ្តុះបណ្តាលមុនពេលចេញដំណើរ និងក្រោយពេលមកដល់ប្រទេសម៉ាឡេស៊ី។

៨- ត្រួតពិនិត្យ និងណែនាំដល់ទីភ្នាក់ងារជ្រើសរើសឯកជននៃប្រទេសទាំងពីរឲ្យគោរពតាមលិខិតបទដ្ឋានគតិយុត្តិរបស់ប្រទេសម៉ាឡេស៊ី និងប្រទេសកម្ពុជា។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

*ថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែធ្នូ គ.ស ២០១៧*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*